## ព្រះទ្រង់ជាអ័ប្បាព្រះវរបិតារបស់យើង

## រ៉ូម ៨:១៥ -អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើឱ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនចញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ ។

អ្វីដែលជាការពិតដ៏អស្ចារ្យ គឺព្រះជាម្ចាស់នៃចក្រវាឡទ្រង់ចង់ឱ្យមានទំនាក់ទំនង

ជាមួយអ្នកក្នុងឋានះជា អ័ប្បារបស់អ្នក ពាក្យអ័ប្បា ជាពាក្យរបស់សាសន៏ហេរព្រឺ មានន័យថា

"ឱពុក" ពេលដែលបុគ្គលណាមួយបានរួចពីទោសនៃអំពើបាប ហើយបានជាដោយមានជំនឿដល់ព្រះយេស៊ូវ ព្រះទ្រង់ប្រាថ្នាចង់បានទំនាក់ទំនង ដ៏ពិសេសជាមួយអ្នក ព្រះទ្រង់ជាអ័ប្បារបស់អ្នក ៗអាចទុកចិត្តលើទ្រង់ដ៏ពេញលេញ ទាំងការពារនឹងផ្គតផ្គង់សំរាប់អ្នកគ្រប់វិស័យទាំងអស់នៅក្នុងជីវិតរបស់អ្នក ហើយ

អ្នកមិនពឹងអាងខ្លួនឯងទៀតទេ អ្នកមានការធានាពីលោកឱពុក "អ័ប្បា" ដែលទ្រង់ចង់ឱ្យអ្នកមានសេចក្តីសុខសាន្តក្នុងព្រះអង្គ ។

ប្រសិនបើអ្នករស់នៅជាមួយឱពុកដែលធ្វើទុកទោសដល់អ្នក មុខជាអ្នកយល់ ឃើយថា ព្រះជាម្ចាស់ក៏ដូចគ្នាដែរ ។ បើអ្នករស់នៅដោយមិនមានឱពុក ឬជាមួយឱពុកដែលគាត់មិនទទួលស្គាល់អ្នក អញ្ចឹងអ្នកនឹងយល់ឃើញថា ព្រះទ្រង់មិនខ្វល់ ខ្វាយ ហើយហាក់ដូចជាទ្រង់ នៅឆ្ងាយដាច់ពីយើងតែម្តង ។ យើងប្រាកដជាបានឃើញព្រះដូចគ្នានឹងដែលយើងជាកូនដែលបានរស់រានមានជីវិតដែរ ។ ហេតុនេះ ហើយជាការសំខាន់ណាស់ ចំពោះឱពុកម្តាយ ដែលបីបាច់ថែរក្សាកូនដោយការទទួលស្គាល់នឹងសេចក្តីស្រឡាញ់ថ្នាក់ថ្នម ។ ដូចជាអ្នកបានប្រគល់ជីវិតទៅឱ្យ ព្រះគ្រប់គ្រង តាមរយះ ព្រះយេស៊ូវគ្រីស្ទ ព្រះអង្គនឹងបង្ហាញទ្រង់ផ្ទាល់ទៅអ្នក ដូចជា អ័ប្បា ព្រះវរបិតា ព្រះអង្គប្រាថ្នាចង់បានការរស់នៅរបៀបនេះជាមួយ អ្នក ការទាំងអស់នេះវានឹងអាចប្រើពេលវេលាយូ ក៏ប៉ុន្តែបើអ្នកមានជំនឿ ស្មោះត្រង់ក្នុងព្រះបន្ទូលទ្រង់និងរស់នៅជាមួយយើងដូចជា អ័ប្បាយព្រះវបិតា

វានឹងអាចមានដែលមនុស្ស ព្យាយាមប្រើថ្នាំសង្កូវដើម្បីព្យាបាល របួសផ្លូវចិត្ត ដែលសោកសង្រេង ។ នេះជាផ្នែកមួយដែលគេព្យាបាលខ្លួនឯង ពីព្រោះគេស្វែង រកមធ្យោបាយបំបាត់សេចក្តីឈឺចាប់ដ៏ជ្រៅនៃសតិអារម្មណ៏ ការឈឺចាប់ទាំងនោះ ត្រូវការព្យាបាល ដោយប្តូរយកនូវសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ ។ នេះជាមូល ហេតុសំខាន់ដែលព្រះវរបិតាបញ្ជូន ព្រះយេស៊ូវគ្រីស្ទយាងមកដើម្បីប្រោសមនុស្ស ដែលមានចិត្តសោកសង្រេង នឹងប្រទានដល់យើងនូវសេចក្តីសុខសាន្ត ដែលយើង ត្រូវការជាចាំបាច់ ។

**Chaplain John P McTernan, Ph.D.**
**USAProphecy.com**
**McTbrochures.com**
**McT911@AOL.com**

## ការអធិស្ឋានសំរាប់អ្នកមានចិត្តសង្រេង

ព្រះជាម្ចាស់ ទូលបង្គំសូមលន់តួសារភាពអំពើបាបរបស់ខ្ញុំ
ចំពោះទ្រង់ ទូលបង្គំជឿជាក់ថា ព្រះយេស៊ូវគ្រីស្ទ
បានខ្ចាយព្រះលោហិត ហើយសុគត់លើឈើឆ្កាង
សំរាប់អំពើបាបទូលបង្គំ ។
ហើយរូបកាយរបស់ព្រះអង្គបានរស់ពីសេចក្តីស្លាប់ឡើងវិញ ។
ទូលបង្គំសូមសារភាពនឹង ទទួលយកទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ
ជាព្រះសង្គ្រោះរបស់ទូលបង្គំ ឥឡូវនេះ ខ្ញុំជឿជាក់ថា
នឹងមានជីវិតអស់កល្បជាមួយទ្រង់ ដូចជា
អ័ប្បាព្រះវរបិតានឹងព្រះជាម្ចាស់នៃទូលបង្គំ ។
ខ្ញុំសូមទូលថ្វាយព្រះវរបិតានឹងប្រោសចិត្តសោកសង្រេងរបស់ខ្ញុំ
ហើយខ្ញុំនឹងអត់ទោសដល់ អ្នកណាដែលធ្វើឱ្យខ្ញុំមានចិត្តសង្រេងដែរ
។ សូមទ្រង់មេត្តាជួយខ្ញុំម្ចាស់ឱ្យរួចពីសេច ក្តី ភ័យខ្លាច ថប់បារម្ភ
ភាពតក់ស្លុត សំអប់ ឈ្នានិស ធ្លាក់ទឹកចិត្ត ល្វីងជូចត់ ការបដិសេធ
មិនទទួលស្គាល់ ហើយឱ បានជៀសផុតពីថ្នាំញៀន សុរា
នឹងគ្រឿងញៀនផងទាំងឡាយ ។
សូមអរព្រះគុណព្រះវរបិតាដែលបានបញ្ជូន
ព្រះយេស៊ូវគ្រីស្ទមកសង្គ្រោះខ្ញុំឱ្យរួចពីបាប ដើម្បីប្រោសចិត្តសង្រេង
ហើយដឹកនាំខ្ញុំទៅរកព្រះអង្គដែលជាអ័ប្បាព្រះវរបិតា ។ ្រះវរបិតា ។

[លោកា ៤: ១៨ -- ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ
ពីព្រោះទ្រង់បានចាក់ព្រេងតាំង
ខ្ញុំឱ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ
ទ្រង់បានចាត់ខ្ញុំឱ្យមកដើម្បីនឹងប្រោសមនុស្ស ដែលមានចិត្តសង្រេង
ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ ពួកឈ្លើយ
នឹងសេចក្តីភ្លឺឡើងវិញ ដល់មនុស្សខ្វាក់
ហើយឱ្យដោះមនុស្សដែលគេជិះជាន់ ។
សេចក្តីប្រោសមនុស្សមានចិត្តសង្រេង
គឺជាការសំខាន់យ៉ាងក្រៃលែងចំពោះព្រះអង្គ
ក៏មិនមែនជាករណីយតូចតាចចំពោះទ្រង់ឡើយ
ប៉ុន្តែជាថ្នាក់បន្ទាប់នៃដំណឹងល្អនៃ
ព្រះយេស៊ូវគ្រីស្ទនឹងសេចក្តីសង្គ្រោះដ៏អស់កល្ប ។
ដោយសារមានសេចក្តីជំនឿដល់ ព្រះយេស៊ូវគ្រីស្ទ
ព្រះជាម្ចាស់បានផ្តល់គ្រប់ទាំងសេចក្តីត្រូវការរស់នៅ នឹងការ
ប្រោសចិត្តសង្រេង ជាមួយភាពពោពេញ
នៃសេចក្តីស្រឡាញ់និងភាពសុខសាន្ត នៃព្រះអម្ចាស់ ។



# ព្រះយេស៊ូវគ្រីស្ទ

## បានយាងមកដើម្បីប្រោសមនុស្ស ដែលមានចិត្តសោកសង្រេង លោកា ៤:១៨

## លូកា ៤:១៨
## ទ្រង់បានចាត់ខ្ញុំឱ្យមកដើម្បីនិងប្រោសមនុស្សដែលមានចិត្តសង្រេង

## អេសាយ ៦១:១
## ទ្រង់ចាត់ខ្ញុំឲ្យទៅចងមនុស្សដែលខូចចិត្ត



## រោគសញ្ញានៃចិត្តសង្រេង

- សេចក្តីខ្លាច:មានសណ្ឋានផ្សេងៗគ្នា
- ការក្រៀមក្រំចិត្ត:ក្តីអស់សង្ឃឹម
- មានអារម្មណ៏កាត់ទោសឥតឈប់ឈរ
- មានអារម្មណ៏នៅឯកកោ:គ្មានអ្នកណាទទួលស្គាល់
- ការនឹកចាំនូវភាពរស់រវើក
នៃសេចក្តីតក់ស្លុតរន្ធត់ចិត្ត

សព្វថ្ងៃនេះបត្តមួយដ៏ធំដែលមានដល់មនុស្សបានប្រើប្រាស់ ថ្នាំញៀន គឺជំងឺធ្លាក់ទឹកចិត្ត ដែលនាំទៅដល់ធ្វើអត្តឃាត ។ ករណីយថ្នាំញៀន ជាទូទៅគេគិតតែអំពី អាភៀន ហេរ៉ូអ៊ីនឬកញ្ឆា នេះជាផ្នែកមួយនៃបញ្ហា ប៉ុន្តែលើសពីនេះទៅទៀត វាជាប់ពាក់ព័ន្ធទៅនឹងថ្នាំផ្សេងៗដូចជា (Pozac) នឹងថ្នាំផ្សេងទៀត ថ្នាំបន្ថយទុក្ខព្រួយ (Antidepressants) ថ្នាំសន្តំ (Valium) ផងនោះ មានមនុស្សរាប់រយលាននាក់នៅក្នុងពិភពលោកយើងនេះ ដែលគេបានប្រើថ្នាំ គ្រប់ប្រភេទ ។ ជាងនេះទៅទៀត មនុស្សជាច្រើនមានការព្រួយបារម្ភ ឈឺចាប់ ភាពតានតឹង ក៏ប៉ុន្តែមិ បានប្រើថ្នាំ ដើម្បីជួយសំរាលទេ ។ ជារៀងរាល់ឆ្នាំ មនុស្សច្រើនណាស់បានកើត ក្នុងករណីយខាងលើនេះ ហើយអត្រាដែលធ្វើអត្តឃាតក៏កើនឡើងដែរ ។ នេះជាបញ្ហាមួយដ៏ធំចំបង ដែលវ នាំឱ្យខូចសុខភាព ទាំងផ្លូវកាយនឹងផ្លូវចិត្ត ដែលបន្តាល ឱ្យមានគ្រោះថ្នាក់ដល់ជីវិត ។ ព្រះគម្ពីបានប្រើពាក្យយ៉ាងរស់រវើក ដើម្បីពិពណ៌នាថាតើមានអ្វីកើតឡើង នៅពេលដែលអ្នកមានចិត្តសង្រេង ។ វាគឺជាទិដ្ឋភាពបែកបាក់ ខ្ទេចខ្ទាំ យ៉ាងឃោឃៅ ដែលមានបំណែកតូចៗពាសពេញ ។ បើសិនជាអ្នកធ្លាប់ឃើញ រូបភាពនៃបំណែកឆ្អឹងបាក់ កដូចគ្នានឹងចិត្តសោកសង្រេង នៃផ្នែកខាងផ្លូវ ចិត្ត ។ ជាមួយចិត្តសង្រេងគឺជាការ កុហក បោះបង់ចោល ភាពឯក កោ កំហឹង ភ័យខ្លាច ខ្វល់ខ្វាយ ស្ពន់ស្លោ សំអប់ នឹងភាពល្វីងជូរចត់ មនោ សច្ចេតនាទាំងនេះដែលនាំឱ្យកើតមានការភ័យស្ពន់ស្លោ ការធ្លាក់ទឹកចិត្ត ហើយត្រូវការថ្នាំព្យាបាល ។ សេចក្តីសោកសង្រេង ទាំងនេះហើយដែលបង្កើត ឱ្យមានអារម្មណ៏នៃបញ្ហា គឺជារោគសញ្ញានៃចិត្តសង្រេង

## អ្វីទៅចិត្តសោកសង្រេង

ការបែកបាក់រវៀងប្តីប្រពន្ធ ( នេះជាការដែលធ្វើឱ្យហិនហោចដល់កូនចៅ ) ការធ្វើបាប ( ទាំងផ្លូវកាយ ផ្លូវចិត្ត នឹងភេទ ) ការបោះបង់ចោល មិនទទួល ស្គាល់ សំអប់ ជម្លោះ ការពន្លូតកូន សោករាជកម្ម និងសេចក្តីស្លាប់ លោកិយ នេះតាក់តែងឡើងនាំឱ្យចិត្តសង្រេង យ៉ាងណាមិញ ពេលដែលមានចិត្តសោក សង្រេង នោះគ្មានអ្វីដែលអាចព្យាបាលបានទេ នៅលើផែនដីនេះ ។ ផ្នែកខាង ចិត្តសាស្រ្តជាមួយនឹងថ្នាំសង្កូវ គ្រប់ប្រភេទក៏មិនអាចព្យាបាលបាន ហើយ គ្រប់ជំហ៊ាននៃកម្មវិធីជួយខ្លួនឯងទៅរកសេចក្តីសុខសាន្តនោះ ក៏មិនអាច ព្យាបាលបានដែរ ។ គ្មានអ្វីទាំងអស់នៅលើផែនដីនេះ ដែលអាចព្យាបាលជំ ងឺចិត្តសោកសង្រេង ពីព្រោះវាជាឫសគុលនៃវិញ្ញាណ អារម្មណ៏ ខាងផ្លូវចិត្ត ការចាត់ចែងនឹងកាត់បន្ថយនៃការប៉ះពាល់ខាងផ្លូវចិត្តសង្រេងនោះ មាន តែព្រះយេស៊ូវគ្រីស្ទតែមួយគត់ ដែលអាចប្រោសឱ្យរួចបាន ។ ចំណាងជើងមួយរបស់ព្រះអង្គ គ្រូពេទ្យដ៏អស្ចារ្យ ដែលព្រះជាម្ចាស់ទ្រង់ បានបញ្ជូនមកដើម្បីព្យាបាលមនុស្សមានចិត្តសង្រេង ។ ប្រសិនបើ ជើងរបស់យើងបាក់ឬស្រាំ លោកគ្រូពេទ្យនិងរៀបឆ្អឹងបាក់ដោយរុំព័ទ កន្លែងបាក់នោះ នេះមានការផ្សាប់ឆ្អឹងបាក់នោះដោយ ខ្នោ វីសនិងរុំព័ទ ដោយព្រួល នេះជាមធ្យោបាយមួយដ៏ពិតប្រាកដដែលគ្រូពេទ្យដ៏អស្ចារ្យ អាចព្យាបាលជំងឺនៃចិត្តសង្រេង ។

ទ្រង់បានយកបំណែកចិត្តដែល ខ្ទិចខ្ទាំមកចងផ្សាប់ ផ្សំឡើងវិញ វានឹងជាសះឡើងវិញហើយជានិរន្ត ។ ព្រះគម្ពីបានបញ្ជាក់ពីចិត្តដែលខ្ទេចខ្ទាំនោះ ជាចិត្តរឹងដូចថ្ម ប៉ុន្តែចិត្ត ដែលប្រោសដោយព្រះយេស៊ូវគ្រីស្ទ ជាចិត្តទន់ នេះជារូបភាពនៃការកែ ប្រែ ឬ ប្តូចិត្តគំនិត ។

## អេសេគាល ៣៦:២៦ អញនឹងឱ្យឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណ ថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្ម ពីរូបសាច់ឯងចេញ រួចនឹងឱ្យមានចិត្តជាសាច់វិញ (ចិត្តទន់) ។

ឥឡូវនេះចិត្តដែលជាសះស្បើយនោះវាទោទន់ស្របជាមួយព្រះជា ម្ចាស់ គឺផ្ទុកដោយសេចក្តីស្រឡាញ់នឹងសេចក្តីសុខសាន្តរបស់ព្រះ ។ គ្រប់ទាំងសញ្ញា អារម្មណ៏ដែលតែងតែធ្វើទារុណកម្មដល់មនុស្ស ឥឡូវ នេះវាបញ្ចប់ជាស្ថាពរហើយយើងមានសេរីភាពក្នុងចិត្តរស់នៅជាមួយ សេចក្តីសុខសាន្តរបស់ព្រះ ។ ដោយអំណាចដ៏ពូកែសាកសិទ្ធនៃព្រះ វិញ្ញាណបរិសុទ្ធ ឥឡូវនេះព្រះទ្រង់អាចសំឡាប់សេចក្តីខ្លាច ខ្វល់ខ្វាយ ថប់បារម្ភ ដែលវាបានធ្វើទារុណកម្មដល់មនុស្ស ។

## ធីម៉ូថេទី២: ១: ៧ ដ្បិតព្រះទ្រង់មិនបានប្រទានឱ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាច សេចក្តីស្រឡាញ់និងប្រាជ្ញានឹងធឹងវិញ ។ ព្រះទ្រង់មានគំរោងការណ៏ព្យាបាល ចិត្តគំនិតយើង ដើម្បីផ្ទុកនូវសេចក្តីស្រឡាញ់និងភាពសុខសាន្តរបស់ ទ្រង់ ។

ដែលយើងបានលូតលាស់ក្នុងព្រះនៃសេចក្តីស្រឡាញ់និងសេចក្តីសុខសាន្តរបស់ព្រះនឹងរីកចំរើនលូតលាស់នៅក្នុងយើងទាំងអស់គ្នាដល់ចំណុចមួយដែលគ្មានអ្វីអាចដកហូតយកសេចក្តីសុខសាន្ត ហើយគ្មានអ្វីអាចបង្ខូរសេចក្តីស្រឡាញ់ចេញពីចិត្តយើងបានទេ ។ ព្រះទ្រង់បានបញ្ជូនព្រះយេស៊ូវគ្រីស្ទ ដើម្បីប្រោសចិត្តសោកសង្រេង ដូច្នេះយើងអាចរស់នៅជាមួយទ្រង់ដពោពេញនូវសេចក្តីស្រឡាញ់ នឹងសេចក្តីសុខសាន្តរបស់ទ្រង់ ។ ជំហានទីមួយក្នុងការព្យាបាលចិត្តសោកសង្រេង គឺជឿដល់ដំ ណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ មុនពេលដែលព្រះអាចព្យាបាលចិត្ត សោកសង្រេង ដែលមានបញ្ហានៃអំពើបាប ដែលយើងត្រូវតែ សារភាពនឹងបង្ហាញអំពើបាបដែលមានភាពធ្ងន់ធ្ងរបំផុត ពីព្រោះតែអំពើបាបទាំងនោះហើយដែលធ្វើឱ្យមនុស្សយើងឃ្លាត ឆ្ងាយពីព្រះជាម្ចាស់ ។ ព្រះបានបញ្ជូនព្រះយេស៊ូវគ្រីស្ទដើម្បីជាស្ពាន ត ភ្ជាប់នៅ ចន្លោះនេះ ។ ឈ្នួលអំពើបាបជាសេចក្តីស្លាប់ ប៉ុន្តែ ព្រះយេស៊ូវ បានខ្ចាយព្រះលោហិតរបស់ទ្រង់ ហើយសុគត់នៅលើឈើឆ្កាង ដើម្បីលោះនៅអំពើបាបរបស់អ្នក គឺមានន័យថា ការអត់អោនទោសទាំងឡាយនឹងមានភាពផ្សះផ្សាឡើងវិញជាមួយព្រះជាម្ចាស់ ដោយមានការលន់តួនិងសារភាពនៃអំពើបាប ។

ជាមួយគ្នានោះ បានផ្តល់នូវការធានានៃជីវិតអស់កល្បជាមួយព្រះជាម្ចាស់ ។ បន្ទាប់ពីបានដោះស្រាយនូវអំពើបាបហើយនោះ ព្រះអង្គ ទ្រង់មានភក្តីភាពដ៏សប្បុរសដែលអាចជួយព្យាបាលចិត្តសោក សង្រេងរបស់យើង ។

## យូហាន ៣:១៦ - តព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឱ្យអ្នកណា ដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមាន ជីវិតអស់កល្បជានិច្ចវិញ ។

ជំហានបន្ទាប់ គឺជាកាពាក់ព័ននៃការអត់អោនទោសចំពោះ អ្នកដ៏ទៃ ។ ការអត់អោនទោសនេះ វាមានការទាក់ទងទៅនឹង បុគ្គលផ្សេងៗ ទៀត ដូចជា ឪពុកម្តាយ ខ្លួនឯងផ្ទាល់ ឬសូម្បីតែការផ្សះផ្សារជាមួយព្រះជាម្ចាស់តាមរយះ ព្រះយេស៊ូវគ្រីស្ទ ។ ព្រះជាម្ចាស់ បានអត់អោនទោសគ្រប់ទាំងអំពើរបាបរបស់យើង ហើយព្រះអង្គទាមទារ ម្រូវឱ្យយើងមានការអត់អោនទោស ដល់អ្នកដែលបានប្រព្រឹត្តកំហុសដល់យើងដែរ ។

## ម៉ាថាយ ៦:១៤ - ដ្បិតបើអ្នករាល់គ្នា អត់ទោសចំពោះការរំលង ច្បាប់ ដែលមនុស្សលោកប្រព្រឹត្តធ្វើ នោះ ព្រះវបិតានៃអ្នកដែល គង់នៅឋានសួគ៏ ទ្រង់នឹងអត់ទោសឱ្យអ្នករាល់ដែរ ។

បើសិនជាអ្នកណាមួយមានអារម្មណ៏ប្រការណាមួយ ដែលធ្វើឱ្យគេមានចិត្តសោកសង្រេងយ៉ាងខ្លាំងដែលគេមិនអាចអត់ ឱនឱ្យបាន ដូច្នេះបុគ្គលនេះ គួតែងាកទៅរកព្រះ ដើម្បីសុំឱ្យ ព្រះអង្គ ប្រទាននូវព្រះគុណ សេចក្តីស្រឡាញ់និងការអត់ទោស ពីទ្រង់ នោះព្រះជាម្ចាស់ទ្រង់នឹងប្រទានឱ្យនូវអ្វីៗដែលអ្នកត្រូវ ការ ដើម្បីឱ្យអ្នកចេះអត់ទោសដល់អ្នកដទៃ ។ ការអត់ទោសនេះ រួមមានខ្លួនឯងផ្ទាល់ផងដែរ មនុស្សខ្លះបាន ប្រព្រិត្តអំពើរបាបដែលគេមានអារម្មណ៏ថា ព្រះទ្រង់មិនអាច អត់អោនទោសបានទេ ។ ជាពិសេសចំពោះស្រ្តីណាដែលបានប្រព្រិត្តរឿងយកកូនក្នុងផ្ទៃ ចេញ ។ ប្រសិនបើនាងសារភាពលន់តួអំពើទាំងនេះ ហើយ ងាកទៅរក ព្រះយេស៊ូវគ្រីស្ទ ហើយយកទ្រង់ជាព្រះសង្គ្រោះរបស់ នាង ព្រះនឹងអត់អោនទោសដល់នាងហើយនាងត្រូវតែ ទទួលយកសេចក្តីអត់អោនទោសពីទ្រង់ ដើម្បីព្យាបាលចិត្ត សោកសង្រេងរបស់នាង ។ អ្នកខ្លះមានកំហឹងប្រឆាំងនឹងព្រះដោយមូលហេតុផ្សេងៗ។ សេចក្តីកំហឹងនេះ ត្រូវតែសារភាពលន់តួចំពោះព្រះជាម្ចាស់ ដើម្បីឱ្យបានជាសះស្បើយនៃចិត្តបុគ្គលនោះ កាលណាបុគ្គល នោះ បានអត់ទោសជាស្ថាពរហើយ ឬអ្នកណាដែលមានចិត្ត សោកសង្រេង ឥឡូវនេះ ព្រះជាម្ចាស់ទ្រង់មានព្រះហរទ័យ ភក្តីនិងប្រោសចិត្តសង្រេង និងឱ្យបានរួចជានិរន្ត ។ សេចក្តីប្រោសមនុស្សមានចិត្តសង្រេង គឺជាការសំខាន់យ៉ាងក្រៃលែងចំពោះព្រះអង្គ ក៏មិនមែនជាករណីយតូចតាចចំពោះទ្រង់ឡើយ ប៉ុន្តែជាថ្នាក់បន្ទាប់នៃដំណឹងល្អនៃ ព្រះយេស៊ូវគ្រីស្ទនឹងសេចក្តីសង្គ្រោះដ៏អស់កល្ប ។ ដោយសារមានសេចក្តីជំនឿដល់ ព្រះយេស៊ូវគ្រីស្ទ ព្រះជាម្ចាស់បានផ្តល់គ្រប់ទាំងសេចក្តីត្រូវការរស់នៅ នឹងការ ប្រោសចិត្តសង្រេង ជាមួយភាពពោពេញ នៃសេចក្តីស្រឡាញ់និងភាពសុខសាន្ត នៃព្រះអម្ចាស់ ។